**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
អគ្គនាយកដ្ឋានអឺរ៉ុប អាមេរិក
និងអាហ្វ្រិក-មជ្ឈិមបូព៌ា

<u>សេចក្តីប្រកាសព័ត៌មាន</u>

# លទ្ធផលនៃកិច្ចពិគ្រោះយោបល់នយោបាយលើកទី៤ រវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការបរទេសនៃសហព័ន្ធស្វ៊ីស

ទីក្រុងប៊ែន ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥៖ ឯកឧត្តម ឃួន ផុនរតនៈ រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តមឯកអគ្គរដ្ឋទូត ហៃនរីហ្ស ឆេលិនប៊ែក (Heinrich Schellenberg) រដ្ឋលេខាធិការទទួលបន្ទុកអាស៊ី-ប៉ាស៊ីហ្វិក នៃក្រសួងការបរទេសស្វ៊ីស បានធ្វើជាសហប្រធាននៃកិច្ចពិគ្រោះយោបល់នយោបាយលើកទី៤ រវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការបរទេសនៃសហព័ន្ធស្វ៊ីស។

ថ្នាក់ដឹកនាំទាំងពីរ បានសម្តែងនូវសេចក្តីពេញចិត្តខ្ពស់ចំពោះចំណងមិត្តភាពដ៏យូរអង្វែង និងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ដែលបាននិងកំពុងបន្តរីកចម្រើនទៅមុខរវាងប្រទេសទាំងពីរ។ ដើម្បីពង្រឹងភាពជាដៃគូនេះឱ្យកាន់តែរឹងមាំ ឯកឧត្តម ឃួន ផុនរតនៈ បានស្នើភាគីទាំងពីរឱ្យបន្តកិច្ចសន្ទនាជាប្រចាំ និងជំរុញឱ្យមានកិច្ចសន្ទនាកម្រិតខ្ពស់នាពេលអនាគត ដែលបានទទួលបានការគាំទ្រយ៉ាងកក់ក្តៅពី ឯកឧត្តមឯកអគ្គរដ្ឋទូត ហៃនរីហ្ស ឆេលិនប៊ែក ។

សហប្រធានទាំងពីរ បានផ្លាស់ប្តូរទស្សនៈគ្នាលើកិច្ចការផ្នែកនយោបាយ សេដ្ឋកិច្ច និងការអភិវឌ្ឍ ដោយកិច្ចពិភាក្សាបានផ្តោតសំខាន់លើកិច្ចសហប្រតិបត្តិការក្នុងវិស័យជាច្រើនដូចជា សុខាភិបាល អភិបាលកិច្ច វិមជ្ឈការ កសិកម្ម ពាណិជ្ជកម្ម ការវិនិយោគ ទេសចរណ៍ បណ្តុះបណ្តាលវិជ្ជាជីវៈ ដោះមីន ជំនួយអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការទាំងក្នុងតំបន់ និងអន្តរជាតិ រួមមានអាស៊ាន និងអង្គការសហប្រជាជាតិ។

ឯកឧត្តម ឃួន ផុនរតនៈ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ តាងនាមរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ជូនដល់ប្រទេសស្វ៊ីស សម្រាប់ការផ្តល់ជំនួយអភិវឌ្ឍន៍ជាបន្តបន្ទាប់ ដែលបានដើរតួយ៉ាងសំខាន់ ក្នុងការរីកចម្រើនរបស់ប្រទេសកម្ពុជា។ ឯកឧត្តម បានគូសបញ្ជាក់អំពីកិច្ចការដ៏អស្ចារ្យរបស់មន្ទីរពេទ្យគន្ធបុប្ផា ក្នុងការប្តេជ្ញាចិត្តយ៉ាងមុតមាំ ដើម្បីផ្តល់សេវាថែទាំសុខភាពឥតគិតថ្លៃប្រកបដោយគុណភាពខ្ពស់ជូនដល់កុមារ និងស្ត្រីកម្ពុជា ហើយបានសង្គ្រោះអាយុជីវិតជាច្រើនរាប់មិនអស់។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

ប្រជាជនកម្ពុជានៅចងចាំជានិច្ច ដោយការដឹងគុណ និងកោតសរសើរយ៉ាងជ្រាលជ្រៅចំពោះដួងវិញ្ញាណក្ខន្ធរបស់ លោកវេជ្ជបណ្ឌិត បឺត រីជន័រ ដែលបានលះបង់កម្លាំងកាយចិត្ត ដោយមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួនក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ បានជួយសង្គ្រោះជីវិតកុមារកម្ពុជារាប់លាននាក់។

ឯកឧត្តមឯកអគ្គរដ្ឋទូត ហៃនរីហ្ស ធេលិនប៉ែក បានកោតសរសើរដល់វឌ្ឍនភាពសេដ្ឋកិច្ចយ៉ាងឆាប់រហ័សរបស់កម្ពុជាក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងមកនេះ ដោយបានឆ្លងកាត់ការវិវត្តយ៉ាងខ្លាំង គឺបានផ្លាស់ប្តូរពីការកសាងឡើងវិញក្រោយសង្គ្រាម មកជាប្រទេសមួយដែលមានសេដ្ឋកិច្ចលូតលាស់លឿនបំផុត នៅអាស៊ីអាគ្នេយ៍។ សហប្រធានទាំងពីរ បានសង្កត់ធ្ងន់លើសារៈសំខាន់នៃការពង្រឹងវិស័យពាណិជ្ជកម្ម និងការវិនិយោគ ខណៈពេលដែលទទួលស្គាល់ថាទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរនៅមានការប្រែប្រួលឡើងចុះនៅឡើយ។ ជាកិច្ចខិតខំប្រឹងប្រែងជំរុញពាណិជ្ជកម្មបន្ថែមទៀត ភាគីទាំងពីរ បានឯកភាពពិចារណាបង្កើតយន្តការពាណិជ្ជកម្មមានប្រសិទ្ធភាពនានា និងជំរុញភាពជាដៃគូអាជីវកម្ម-និង-អាជីវកម្ម និងបន្តកិច្ចពិភាក្សាពិនិត្យលទ្ធភាពបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងប្រទេសទាំងពីរ ដើម្បីធ្វើពិពិធកម្មទីផ្សារនាំចេញ។

ភាគីទាំងពីរ មានជំនឿជឿជាក់យ៉ាងមុតមាំថា បន្ទាត់ស្របគ្នារវាងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា និងអាទិភាពកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់ប្រទេសស្វ៊ីស ផ្តល់នូវក្របខ័ណ្ឌយ៉ាងរឹងមាំមួយ សម្រាប់កិច្ចសហការកាន់តែស៊ីជម្រៅ។ យុទ្ធសាស្ត្រទាំងពីរនេះផ្តោតលើវិស័យសំខាន់ៗដូចជា ការអភិវឌ្ឍមូលធនមនុស្ស ការធ្វើពិពិធកម្មសេដ្ឋកិច្ច ការអភិវឌ្ឍប្រកបដោយចីរភាព នវានុវត្តន៍ឌីជីថល និងអភិបាលកិច្ច។ ភាពស៊ីចង្វាក់គ្នានេះ ផ្តល់នូវមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការបន្តភាពជាដៃគូដើម្បីទ្រទ្រង់ដល់ការសម្រេចចក្ខុវិស័យរបស់កម្ពុជាឆ្នាំ ២០៥០។

ក្នុងកិច្ចប្រជុំ ក៏បានពិភាក្សាអំពីបញ្ហាតំបន់ និងពិភពលោក ព្រមទាំងការវិវត្តយ៉ាងឆាប់រហ័សនៃពាណិជ្ជកម្មសកលផងដែរ។ ភាគីទាំងពីរ បានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តរួមគ្នា ក្នុងការលើកកម្ពស់សន្តិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់អន្តរជាតិផ្អែកលើច្បាប់ តាមរយៈកិច្ចសន្ទនាបែបស្ថាបនា និងកិច្ចសហប្រតិបត្តិការជិតស្និទ្ធ។

ជាកិច្ចសន្និដ្ឋាន កិច្ចពិគ្រោះយោបល់នយោបាយ បានប្រព្រឹត្តទៅប្រកបដោយភាពជោគជ័យ ក្នុងបរិយាកាសកក់ក្តៅ និងស្និទ្ធស្នាល ដែលបានឆ្លុះបញ្ចាំងអំពីមិត្តភាពយូរអង្វែង និងការគោរពគ្នាទៅវិញទៅមក ក្នុងទំនាក់ទំនងរវាងកម្ពុជា និងស្វ៊ីស។ សហប្រធានទាំងពីរ ទន្ទឹងរៀបចំកិច្ចពិគ្រោះយោបល់នយោបាយជុំបន្ទាប់ ដែលនឹងប្រព្រឹត្តទៅនៅកម្ពុជា តាមកាលបរិច្ឆេទសមស្របទៅវិញទៅមក។

ថ្ងៃ ចន្ទ ១៣រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៣ខែមិថុនា ឆ្នាំ២០២៥